**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ឆ្នាំង**
**លេខ** ៖ ៤.៧៧៣./២៣ សសណា

# សេចក្តីជូនដំណឹង

**យោង** : - លិខិតលេខ ៣៦០/២៣លស ចុះថ្ងៃព្រហស្បតិ៍ ៨កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ ត្រូវថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ របស់រដ្ឋបាលខេត្ត ស្តីពីការកំណត់តម្លៃមូលដ្ឋានភាសីគ្រប់ប្រភេទ

- លិខិតលេខ ១០០៦០សហវ.លស.អទច ចុះថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ត្រូវថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការរៀបចំដាក់ឲ្យដេញថ្លៃភាសីគ្រប់ប្រភេទ សម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៤ តាមនីតិវិធីដេញថ្លៃជាសាធារណៈ និងជំរុញការប្រមូលចំណូលបង់ចូលថវិកាខេត្ត ។

រដ្ឋបាលខេត្តកំពង់ឆ្នាំង សូមជម្រាបជូនដំណឹងដល់បងប្អូនអតិថិជនទាំងពីរភេទ ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ( លើកលែងមន្ត្រីរាជការ និយោជិក និស្សិត និងសិស្ស ) សូមជ្រាបថា៖ **នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ចាប់ពីម៉ោង ០៨:០០នាទីព្រឹក** រដ្ឋបាលខេត្តកំពង់ឆ្នាំងនឹងរៀបចំកម្មវិធីដេញថ្លៃភាសីគ្រប់ប្រភេទ សម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៤ តាមនីតិវិធីដេញថ្លៃជាសាធារណៈ និងជំរុញការប្រមូលចំណូលបង់ចូលថវិការដ្ឋបាលខេត្ត ដែលនឹងប្រព្រឹត្តទៅនៅសាលប្រជុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង ។ ដូច្នេះសូមអតិថិជនទាំងពីរភេទ ដែលមានបំណងចូលរួមដេញថ្លៃភាសីគ្រប់ប្រភេទ សម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៤ តាមនីតិវិធីដេញថ្លៃជាសាធារណៈ និងជំរុញការប្រមូលចំណូលបង់ចូលថវិការដ្ឋបាលខេត្តកំពង់ឆ្នាំង សូមអញ្ជើញមកទំនាក់ទំនងរកពាក្យសុំដេញថ្លៃ **ចាប់ពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ០៨:០០នាទីព្រឹក រហូតដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ១២ថ្ងៃត្រង់ នៅការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ និងការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ** នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង។

**តារាងកំណត់ថ្លៃមូលដ្ឋានភាសីគ្រប់ប្រភេទ**
**សម្រាប់ដាក់ឲ្យដេញថ្លៃធ្វើអាជីវកម្មឆ្នាំ២០២៤ ទូទាំងខេត្តកំពង់ឆ្នាំង**
**កាលបរិច្ឆេទដេញថ្លៃនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣** ឯកត្តា: រៀល

| ល.រ | មុខសញ្ញាភាសី | តម្លៃមូលដ្ឋាន ឆ្នាំ២០២៤ | ផ្សេងៗ |
|---|---|---|---|
| | **សរុបរួម** | **20,000,000៛** | |
| | **ក/ ភាសីផ្សារ** | **16,000,000៛** | |
| ១ | ផ្សារឆ្នាំង (ក្រុងកំពង់ឆ្នាំង) | 12,000,000៛ | |
| ២ | ផ្សារសែប តាជេសក្រោម (ស្រុកកំពង់ត្រឡាច) | 4,000,000៛ | |
| | **ខ/ ចំណតយានជំនិះ:** | **4,000,000៛** | |
| ៣ | ស្រុកទឹកផុស | 4,000,000៛ | |

☆ **សម្គាល់:** ការដេញថ្លៃភាសីសត្តឃាតដ្ឋានសម្រាប់រយៈពេល ៣(បី)ឆ្នាំម្តង ។

អាសយដ្ឋានសាលាខេត្តកំពង់ឆ្នាំង:ភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ទូរស័ព្ទលេខ:(៨៥៥)០២៦ ៩៨៨ ៦៥២
សារអេឡិចត្រូនិច: info@kampongchhnang.gov.kh គេហទំព័រ: www.kampongchhnang.gov.kh

**សំណុំលិខិតឯកសារ និងលក្ខខណ្ឌនៃការដេញថ្លៃរបស់អតិថិជនរួមមាន ÷**

១/ពាក្យសុំដេញថ្លៃមានបិទតែមប្រិយ៍សារពើពន្ធ(មានគំរូ)ចំនួន ០២ច្បាប់
២/រូបថត ៤ គុណ ៦ ចំនួន ០២សន្លឹក
៣/អត្តសញ្ញាណប័ណ្ណថតចម្លងចំនួន (ច្បាប់ដើមធ្វើការផ្ទៀងផ្ទាត់) ០២ច្បាប់
៤/បង្កាន់ដៃបង់ប្រាក់ធានាបណ្ដោះអាសន្នចេញដោយធនាគារខេត្តស្មើនឹង២០%តម្លៃមូលដ្ឋាន ០១ច្បាប់
៥/ធនធាន ឬអចលនៈវត្ថុធានារបស់សាមីខ្លួនដែលមានតម្លៃ ៥០% នៃតម្លៃមូលដ្ឋានដោយមានការវាយតម្លៃបញ្ជាក់ពីមេឃុំ ចៅសង្កាត់ ០១ច្បាប់
៦/ពន្ធប៉ាតង់ធ្វើអាជីវកម្មប្រចាំឆ្នាំ និងបានបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវសម្រាប់ឆ្នាំកន្លងមក ០១ច្បាប់
៧/កិច្ចសន្យាប្រគល់ប្រាក់ធានាបណ្ដោះអាសន្នជូនរដ្ឋ ០២ច្បាប់
៨/កិច្ចសន្យាប្រគល់ប្រាក់ធានាស្ថាពរជូនរដ្ឋ ០២ច្បាប់
៩/កិច្ចសន្យាស្ដីពីការប្រតិបត្តិតាមសៀវភៅបន្ទុក ០២ច្បាប់
១០/ចំពោះអតិថិជនអាជីវករ ប្រជាពលរដ្ឋ ០១រូប មានសិទ្ធិដាក់ពាក្យសុំដេញថ្លៃបានយ៉ាងច្រើន ០៣មូលដ្ឋាន អាជីវកម្មតែប៉ុណ្ណោះ ដោយមិនអនុញ្ញាតិឲ្យយកគ្រួសារ ឬបងប្អូនមកដាក់ជំនួសបានឡើយ
១១/អតិថិជនមុនដាក់ពាក្យសុំដេញថ្លៃ សូមពិនិត្យលក្ខខណ្ឌដែលកំណត់នៅក្នុងសៀវភៅបន្ទុកជូនភ្ជាប់ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមអតិថិជនទាំងពីរភេទដែលមានបំណងចូលរួមដេញថ្លៃភាស៊ីគ្រប់ប្រភេទ សម្រាប់ដាក់ឲ្យធ្វើអាជីវកម្មឆ្នាំ២០២៤ តាមនីតិវិធីដេញថ្លៃជាសាធារណៈ និងជំរុញការប្រមូលចំណូលបង់ចូលថវិការដ្ឋបាលខេត្ត សូមអញ្ជើញមកទំនាក់ទំនងរកពាក្យសុំដេញថ្លៃភាស៊ីគ្រប់ប្រភេទ **នៅការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ និងការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង** តាមពេលវេលាម៉ោងធ្វើការដាក់កំហិត។

ថ្ងៃពុធ ១១ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅខេត្តកំពង់ឆ្នាំង ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០២៣
**អភិបាលខេត្តកំពង់ឆ្នាំង**

ស៊ុន សុវណ្ណារិទ្ធិ

**ចម្លងជូន ÷**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង
  *"ដើម្បីគោរពជូនជ្រាប"*
- ឯកសារ កាលប្បវត្តិ